European Union
Delegation to Cambodia

# គម្រោងចំនួនបួន ដែលទទួលបានថវិកាពីសហភាពអឺរ៉ុប ដើម្បីគាំទ្រសហគមន៍នេសាទ ក្នុងខេត្តជុំវិញបឹងទន្លេសាប និងខេត្តដែលស្ថិតនៅតាមតំបន់ឆ្នេរ ត្រូវបានប្រកាសចាប់ផ្តើមអនុវត្ត

**រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២១៖** ថ្ងៃនេះ ប្រតិភូសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមនឹងអង្គការ WCS, Oxfam, Aide et Action, និង Save the Children បានប្រកាសជាផ្លូវការពីការចាប់ផ្តើមអនុវត្តគម្រោងចំនួនបួន ដែលទទួលបានថវិកាពីសហភាពអឺរ៉ុប ដើម្បីគាំទ្រដល់កំណើនបៃតង ការបង្កើតការងារ ការផ្តល់សេវាសង្គម និងការការពារធនធានធម្មជាតិឱ្យរឹតតែប្រសើរសម្រាប់សហគមន៍នេសាទក្នុងខេត្តចំនួន ១០ ដែលស្ថិតនៅតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប និងតំបន់ឆ្នេរ។

សិក្ខាសាលាប្រកាសចាប់ផ្តើមគម្រោង ដែលធ្វើឡើងរួមគ្នាតាមប្រព័ន្ធអនឡាញនៅថ្ងៃនេះ មានអ្នកចូលរួមប្រមាណ ៣២០នាក់ មកពីក្រសួងពាក់ព័ន្ធ អាជ្ញាធរខេត្ត ក្រុមការងារបច្ចេកទេស វិស័យជលផលសហគមន៍នេសាទ អង្គការក្រៅរដ្ឋាភិបាល រួមនឹងដៃគូចូលរួមអនុវត្ត រដ្ឋជាសមាជិកសហភាពអឺរ៉ុប និងដៃគូអភិវឌ្ឍន៍ដទៃទៀត។

ប្រធានទទួលបន្ទុកកិច្ចសហប្រតិបត្តិការនៃប្រតិភូសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា លោក Bryan Fornari មានប្រសាសន៍ថា "កម្មវិធី CAPFISH គឺជាកម្មវិធីទ្វេភាគីធំជាងគេដំបូងបង្អស់របស់សហភាពអឺរ៉ុបនៅកម្ពុជា ដែលមានគោលដៅជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយ បរិយាប័ន្ន ចីរភាព និងធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ សម្រាប់វិស័យជលផល។ តាមរយៈការសហការជាមួយនឹងរដ្ឋបាលជលផល ព្រមទាំងដៃគូរអនុវត្តរបស់យើង ការប្រកាសចាប់ផ្តើមអនុវត្តគម្រោងទាំងបួននៅថ្ងៃនេះ គឺជាសមិទ្ធផលដ៏សំខាន់សម្រាប់ការស្តារឡើងវិញពីជំងឺកូវីដ-១៩ នៅក្នុងតំបន់នេះ តាមរយៈការនាំមកនូវឱកាសសេដ្ឋកិច្ចថ្មីៗ និងការកសាងជីវភាពរស់នៅឲ្យកាន់តែប្រសើរឡើង សម្រាប់ប្រជាពលរដ្ឋជាងប្រាំម៉ឺន (៥០.០០០) គ្រួសារ។ ភាពជាដៃគូរបស់យើងជាមួយនឹងរដ្ឋបាលជលផល នឹងជួយឱ្យយើងអាចសម្រេចគោលដៅនេះបាន"។

ឯកឧត្តម ពុំ សុថា អគ្គនាយកនៃរដ្ឋបាលជលផលមានប្រសាសន៍ថា "រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសេនាធិការ សូមសម្តែងនូវសេចក្តីថ្លែងអំណរគុណ និងការវាយតម្លៃខ្ពស់ចំពោះសហភាពអឺរ៉ុប ដែលបានផ្តល់ការឧបត្ថម្ភដល់កម្មវិធីធំបំផុតដែលមិនធ្លាប់មានសម្រាប់អភិវឌ្ឍវិស័យជលផលនៅកម្ពុជា"។

លោកស្រី Pearce មានប្រសាសន៍ថា "អង្គការ Save the Children ពិតជាមានចិត្តរំភើបរីករាយ ដែលអាចសហការជាមួយនឹងដៃគូនានា សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងសហគមន៍នេសាទងាយរងគ្រោះ នៅភាគខាងកើតនៃតំបន់ទន្លេសាប និងជាពិសេសជំរុញឱ្យមានការអនុវត្តនូវគំនិតផ្តួចផ្តើមសេដ្ឋកិច្ចបៃតង និងការអនុវត្តល្អផ្នែកបរិស្ថាន ហើយក្នុងពេលជាមួយគ្នាជួយឱ្យកុមារ និងគ្រួសារទទួលបានសេវាកម្ម ប្រកបដោយគុណភាព សុវត្ថិភាព និងបរិយាប័ន្ន សម្រាប់ការ អប់រំ ទឹកស្អាត អនាម័យ និងសេវាគ្រប់គ្រងសំណល់"។

លោក វន សម្ផស្ស នាយកប្រចាំប្រទេសនៃអង្គការ Aide et Action Cambodia មានប្រសាសន៍ថា "ភាពជាដៃគូ CO-SAVED Cambodia មានការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះ ដូចជា វិស័យឯកជន រដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីជំរុញឲ្យមានវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ យើងប្តេជ្ញាផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋកម្ពុជាចំនួន ៣៨២.៦៥០នាក់ ដែលរស់នៅក្នុងសហគមន៍តាមតំបន់ឆ្នេរក្នុងការបង្កើតភាពជាដៃគូយូរអង្វែង ដើម្បីលើកកម្ពស់កំណើនសេដ្ឋកិច្ចបៃតងប្រកបដោយបរិយាប័ន្ន ការផ្តល់សេវាអប់រំ ទឹកស្អាត និងអនាម័យប្រកបដោយគុណភាព និងការមានជីវភាពរស់នៅប្រកបដោយចីរភាព" ។

បណ្ឌិត កែន សិរីរដ្ឋា នាយកប្រចាំប្រទេសនៃអង្គការអភិរក្សសត្វព្រៃ (WCS) មានប្រសាសន៍ថា "គម្រោងទន្លេសាបរបស់យើង មានសារៈសំខាន់សម្រាប់ជីវចម្រុះ ធនធានជលផល មុខរបរចិញ្ចឹមជីវិត សុខុមាលភាព និងវប្បធម៌ ប៉ុន្តែបឹងរបស់យើងកំពុងបាត់បង់រូបរាងយ៉ាងឆាប់រហ័ស ដោយសារតែការប្រែប្រួលអាកាសធាតុ ការសាងសង់ទំនប់វារីអគ្គិសនី និងការបង្វែរទឹកពីតាមដៃទន្លេសម្រាប់ ប្រព័ន្ធស្រោចស្រពក្នុងវិស័យកសិកម្ម។ យើងត្រូវចាប់យកឱកាស ដើម្បីកសាងភាពធន់នៃប្រព័ន្ធអេកូឡូស៊ី សហគមន៍ និងជីវៈចម្រុះ ដើម្បីបញ្ចៀសគ្រោះមន្តរាយមកលើមនុស្ស និងប្រព័ន្ធអេកូឡូស៊ី"។

## សាវតារនៃគម្រោងទាំងបួន

អង្គការ Save the Children (REDD BARNA) ដោយមានការគាំទ្រថវិកា ៤លានអឺរ៉ូ ពីសហភាពអឺរ៉ុប កំពុងផ្តល់ការគាំទ្រដល់សហគមន៍នេសាទក្នុងខេត្តពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ធំ ដើម្បីលើកកម្ពស់ស្ថានភាពសង្គម-សេដ្ឋកិច្ច ព្រមទាំងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត និងអនាម័យ ប្រព័ន្ធគ្រប់គ្រងសំណល់ គំនិតផ្តួចផ្តើមសេដ្ឋកិច្ចបៃតង និងការអប់រំ។

អង្គការ Oxfam ជាមួយនឹងជំនួយថវិកា ៤លានអឺរ៉ូ ពីសហភាពអឺរ៉ុប កំពុងអនុវត្តគម្រោងរយៈពេល ៤ ឆ្នាំ (២០២១-២០២៤) ដើម្បីគាំទ្រដល់សហគមន៍នេសាទក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប ក្នុងការលើកកម្ពស់លទ្ធភាពទទួលបាននូវការផ្គត់ផ្គង់ទឹកស្អាត សេវាអប់រំ សេវាអនាម័យ សេវាគ្រប់គ្រងសំណល់ ការគ្រប់គ្រងធនធានធម្មជាតិសហគមន៍ប្រកបដោយចីរភាព ក៏ដូចជា លើកកម្ពស់ឱកាសប្រកបមុខរបរចិញ្ចឹមជីវិត និងឱកាសការងារ។

អង្គការ Aide et Action Association ជាមួយនឹងថវិកាចំនួន ៤ លានអឺរ៉ូ ពីសហភាពអឺរ៉ុប កំពុងអនុវត្តគម្រោងរយៈពេល ៤ឆ្នាំ (២០២១-២០២៤) ដើម្បីគាំទ្រដល់សហគមន៍ក្នុងខេត្តកែប កំពត ក្រុងព្រះសីហនុ និងខេត្តកោះកុង ឱ្យកាន់តែមានភាពធន់ តាមរយៈការអភិវឌ្ឍសេដ្ឋកិច្ចក្នុងមូលដ្ឋានប្រកបដោយចីរភាព ការផ្តល់សេវាកម្មកាន់តែប្រសើរឡើង និងកំណើនបៃតង ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងវិសមភាពសង្គម។

អង្គការអភិរក្សសត្វព្រៃ (WCS) ក្រសួងបរិស្ថាន និងដៃគូ ដែលបានទទួលជំនួយថវិកា ៤,៩លានអឺរ៉ូ ពីសហភាពអឺរ៉ុប កំពុងអនុវត្តគម្រោងរយៈពេល៤ឆ្នាំ (២០២១-២០២៤) នៅក្នុងខេត្តសៀមរាប កំពង់ធំ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីធ្វើឱ្យកាន់តែប្រសើរនូវការគ្រប់គ្រង និងការស្តារដែនជម្រកសំខាន់ៗ សំដៅជួយបង្កើនភាពធន់នឹង ការប្រែប្រួលបរិស្ថាន ក៏ដូចជា ជួយលើកកម្ពស់អភិបាលកិច្ច និងគោលនយោបាយ សំដៅកាត់បន្ថយកត្តាបង្កឱ្យមានការប្រែប្រួលបរិស្ថាន។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងលោកស្រី ប៉ុក ពូន មន្ត្រីសារព័ត៌មាននៃប្រតិភូសហភាពអឺរ៉ុប តាមរយៈទូរស័ព្ទ ០២៣ ២២០ ៦១១ ឬអ៊ីមែល pok.poun@eeas.europa.eu។*